**មាត្រា ៥.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០១

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យលេខ ៣៩ អនក្រ.បក**

**ស្តីពី**

**ការបង្កើតឃុំតាគ្រី**

**ចំណុះស្រុកកំរៀង ខេត្តបាត់ដំបង**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករាឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា១.-** ត្រូវបានបង្កើតឃុំតាគ្រី ចំណុះស្រុកកំរៀង ខេត្តបាត់ដំបង ដោយកាត់យកពីភូមិសាស្ត្រ ឃុំអូរដា ឃុំតាសែន នឹងឃុំត្រាង នៃស្រុកកំរៀង ខេត្តបាត់ដំបង ។

**មាត្រា២.-** ឃុំ តាគ្រី មានព្រំប្រទល់រដ្ឋបាលដូចខាងក្រោមៈ

- ខាងកើតទល់នឹង ស្រុកបវេល ខេត្តបាត់ដំបង
- ខាងលិចទល់នឹង ឃុំ អូដារ ឃុំ តាសែន ឃុំ ត្រាង នឹង ឃុំ កំរៀង ស្រុក កំរៀង ខេត្តបាត់ដំបង

- ខាងជើងទល់នឹង ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

- ខាងត្បូងទល់នឹង ខ័ណ្ឌសាលាក្រៅ ក្រុងប៉ៃលិន

**មាត្រា ៣.-** ទីតាំងរដ្ឋបាលសាលាឃុំ តាក្រីស្ថិតនៅក្នុងភូមិកំប្រង់ ។

**មាត្រា ៤.-** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនិងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈ រដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអ នុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០១

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ៤០ អនក្រ.បក

## ស្តីពី

## ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់

## នៃព្រះរាជាណាចក្រកម្ពុជា

~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
~~~